# ច្បាប់សិទ្ធិអ្នកបោះឆ្នោត នៃរដ្ឋម៉ាសាឈូសេត្ស Massachusetts Voters' Bill of Rights

## *សិទ្ធិបោះឆ្នោតរបស់អ្នកបានការពារអ្នក ។ សិទ្ធិនេះត្រូវបានធានាពេញលេញ ចំពោះអ្នកដែលបានចុះឈ្មោះបោះឆ្នោត ។*

**1- *អ្នកមានសិទ្ធិ*** *បោះឆ្នោត បើសិនជាអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ ។*

**2- *អ្នកមានសិទ្ធិ*** *បោះឆ្នោត នូវសន្លឹកឆ្នោតរបស់អ្នកមានលក្ខណៈសំងាត់ ។ អ្នកមានសិទ្ធិបោះឆ្នោត ដោយគ្មាននរណាមកយាយី ឬរំខានដល់ការបោះឆ្នោតរបស់អ្នក និងបោះឆ្នោតនៅក្នុងស្ថានីយ៍បោះឆ្នោត ឬគ្មាននរណាម្នាក់មើលអ្នកគូសលើសន្លឹកឆ្នោតរបស់អ្នកឡើយ ។*

**3- *អ្នកមានសិទ្ធិ*** *បោះឆ្នោតរយៈពេល 5នាទីនៅក្នុងស្ថានីយ៍បោះឆ្នោត បើសិនជាមានអ្នកបោះឆ្នោតផ្សេងទៀតនៅឈររង់ចាំ និង រយៈពេល 10នាទី បើសិនមិនមានអ្នកបោះឆ្នោតឈររង់ចាំ ។*

**4- *អ្នកមានសិទ្ធិ*** *ប្តូរសន្លឹកឆ្នោតគូសខុសលើសពី 2 សន្លឹក បើសិនអ្នកគូសខុស និងលុប លើសន្លឹកឆ្នោតរបស់អ្នក ។*

**5- *អ្នកមានសិទ្ធិ*** *ស្នើរសុំជំនួយការនៅពេលបោះឆ្នោត ពីអ្នកធ្វើការនៅក្នុងស្ថានីយ៍បោះឆ្នោត ឬនរណាម្នាក់ពីការជ្រើសរើសរបស់អ្នក ។*

**6- *អ្នកមានសិទ្ធិ*** *បោះឆ្នោតបើសិនអ្នកអសមត្ថភាព ។ ស្ថានីយ៍បោះឆ្នោតត្រូវតែមានលក្ខណៈងាយស្រួល និងត្រូវតែងាយស្រួលក្នុងការបោះឆ្នោត ។*

**7- *អ្នកមានសិទ្ធិ*** *បោះឆ្នោតបើសិនជាអ្នកមិនអាចអាន ឬសរសេរ ឬមិនអាចអាន សរសេរ ជាភាសាអង់គ្លេស ។*

**8- *អ្នកមានសិទ្ធិ*** *បោះឆ្នោត ប៉ុន្តែអ្នកត្រូវតែបង្ហាញអត្តសញ្ញាណប័ណ្ណសំគាល់ខ្លួនបើសិនអ្នកជា ៖ អ្នកបោះឆ្នោតលើកដំបូង (លើកទី1) ដែលបានចុះឈ្មោះបោះឆ្នោតរួចហើយ បោះឆ្នោតតាមរយៈសំបុត្រមិនបញ្ជាក់អត្តសញ្ញាប័ណ្ណ ជាមួយនិងពាក្យចុះឈ្មោះបោះឆ្នោត ឬឈ្មោះរបស់អ្នកមិនមែន ជាអ្នកបោះឆ្នោតសកម្មក្នុងបញ្ជីអ្នកបោះឆ្នោត ឬការបោះឆ្នោតរបស់អ្នក បានកែតម្រូវ ឬបើសិនបានស្នើរសុំ តាមរយៈមន្ត្រីធ្វើការបោះឆ្នោតនៅឯស្ថានីយ៍ ។ ប័ណ្ណដែលទទួលស្គាល់នៃអត្តសញ្ញាប័ណ្ណមានដូចជា ៖ ប័ណ្ណបើកយានយន្តនៃរដ្ឋម៉ាស្សាឈូ - ស្សេតរបស់អ្នក ឯកសារដទៃទៀតដែលបានបោះពុម្ពភ្ជាប់ ឈ្មោះ និងអសយដ្ឋានរបស់អ្នក ដូចជាវិកិយប័ត្រទឹក ភ្លើង ទូរស័ព្ទពេលថ្មីៗ វិកិយប័ត្រជួលផ្ទះដោយមានសំបុត្របញ្ជាក់ពីម្ចាស់ផ្ទះ កិច្ចសន្យាជួល ឬកូបពីពាក្យចុះឈ្មោះបោះឆ្នោត ឬបង្កាន់ដៃ ដែលទទួលស្គាល់ ។*

**9- *អ្នកមានសិទ្ធិ*** *បោះឆ្នោតដោយសន្លឹកឆ្នោតអវត្តមាន បើសិនអ្នកនិងអវត្តមានដោយចាកចេញពីទីក្រុងរបស់អ្នក នៅថ្ងៃបោះឆ្នោត ឬបើសិនអ្នកមានកាយសម្បទា (រូបរាងកាយ) ពិការ ដែលជាមូលហេតុរបស់អ្នកដែលមិនអាចបោះឆ្នោតបាន នៅឯស្ថានីយ៍បោះឆ្នោត បើសិនជាអ្នកមិនអាចទៅបោះឆ្នោតបាននៅស្ថានីយ៍បោះឆ្នោត នៅថ្ងៃកំណត់ដោយសារជំនឿសាសនា ។*

**10- *អ្នកមានសិទ្ធិ*** *បោះឆ្នោត លើសន្លឹកឆ្នោតបណ្តោះអសន្ន បើសិនជាអ្នកមានជំនឿថាអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមន្ត្រីបោះឆ្នោតនៅឯស្ថានីយ៍ប្រាប់ថា អ្នកគ្មានសិទ្ធិបោះឆ្នោតក៏ដោយ ។*

**11- *អ្នកមានសិទ្ធិ*** *យោងទៅតាមការកែតម្រូវនិមួយៗ សិទ្ធិបោះឆ្នោតរបស់អ្នកសំដៅទៅតាមការបណ្តឹងជាលំដាប់លំដោយ ។*

**12- *អ្នកមានសិទ្ធិ*** *បោះឆ្នោតបើសិនអ្នក មិនជាប់គុកក្នុងបច្ចុប្បន្ននេះ សំរាប់ការកាត់អោយជាប់ទោសបទឧក្រិដ្ឋ និងបានចុះឈ្មោះបោះឆ្នោតរួចហើយ អ្នកក៏ដូចជាអ្នកបោះឆ្នោតម្នាក់ដែល បន្ទាប់ពីអ្នករួចផុតពីការជាប់ទោស ។*

**13- *អ្នកមានសិទ្ធិ*** *យកច្បាប់សិទ្ធិបោះឆ្នោត ឬឯកសារផ្សេងៗទៀត រួមទាំងបញ្ជីរាយឈ្មោះអ្នកឈរឈ្មោះបោះឆ្នោត មគ្គុទ្ទេសក៍ (ណែនាំ) អ្នកបោះឆ្នោត ឬសំភារៈឃោសនាចូលក្នុងស្ថានីយ៍បោះឆ្នោតជាមួយអ្នក ។ សូមមេត្តាចងចាំថា យកឯកសារទាំងអស់ចេញពីកន្លែងបោះឆ្នោត បន្ទាប់ពីអ្នកចាកចេញពីស្ថានីយ៍បោះឆ្នោត ។*

**14- *អ្នកមានសិទ្ធិ*** *បោះឆ្នោតនៅឯស្ថានីយ៍បោះឆ្នោតនៅពេលណាក៏បានចាប់ពីម៉ោង 7:00ព្រឹក រហូតដល់ ម៉ោង 8:00យប់ សំរាប់បោះឆ្នោតរដ្ឋ និងសហព័ន្ធ ម៉ោងប្រែប្រួលទៅតាមការបោះឆ្នោតក្នុងតំបន់ ។ បើសិនជាអ្នកឈររង់ចាំបោះឆ្នោតនៅឯស្ថានីយ៍បោះឆ្នោត ក្នុងពេលដែលស្ថានីយ៍បោះឆ្នោតបិទនៅម៉ោង៨យប់ អ្នកមានសិទ្ធិបោះឆ្នោត ។*

**15- *អ្នកមានសិទ្ធិ*** *នាំកូនចូលទៅស្ថានីយ៍បោះឆ្នោតជាមួយអ្នក ។ ក្មេងមិនអាចគូសលើសន្លឹកឆ្នោតបានទេ ។*

*បើសិនអ្នកមានអារម្មណ៍ថា សិទ្ធិបោះឆ្នោតរបស់អ្នក ត្រូវបានគេប្រព្រឹត្តល្មើសច្បាប់តាមវិធីណាមួយ សូមទូរស័ព្ទទៅ* the Secretary of the Commonwealth's Election Division *លេខ* 1-800-462-8683 *ទូរស័ព្ទលេខនេះមិនគិតថ្លៃ នៅក្នុងរដ្ឋម៉ាស្សាឈូសេត្ស*

Document Produced by deskPDF Unregistered :: http://www.docudesk.com

**Mitt Romney**
Governor of the Commonwealth
of Massachusetts

**William F. Galvin**
Secretary of the Commonwealth
of Massachusetts

**Madhu Sridhar**
President
League of Women Voters
of Massachusetts

*រៀបចំដោយ សហគមន៍ស្ត្រីបោះឆ្នោត នៃរដ្ឋម៉ាស្សាឈូស្សេត ខែមករា 2006*

**Prepared by the League of Women Voters of Massachusetts, January 2006**

Document Produced by deskPDF Unregistered :: http://www.docudesk.com